# សេចក្តីប្រកាសព័ត៌មានរបស់សហចៅក្រមស៊ើបសួរ

## ថ្ងៃទី ១ ខែ វិច្ឆិកា ឆ្នាំ ២០០៧

ដើម្បីអោយសាធារណៈជនបានដឹងអំពីស្ថានភាពរីកចំរើននៃដំណើរការតុលាការដែលកំពុងមាន សហចៅក្រមស៊ើបអង្កេតនៃអង្គជំនុំជម្រះវិសាមញ្ញសូមធ្វើសេចក្តីប្រកាសព័ត៌មានដូចខាងក្រោម ៖

1- **ស្ថានភាពសុខភាពរបស់ជនជាប់ឃុំ នួន ជា**

ដោយសារជនជាប់ឃុំនេះត្អូញត្អែរអំពីបញ្ហាទាក់ទងនឹងការឡើងសំពាធឈាម យើងបានបង្គាប់អោយមានកោសលវិច័យផ្នែកវេជ្ជសាស្ត្រមួយ។ លោក នួន ជា ត្រូវបានពិនិត្យដោយគ្រូពេទ្យជំនាញ ៣ រូបជាបន្តបន្ទាប់។ គាត់ត្រូវបានពិនិត្យសុខភាពស៊ីជម្រៅ ដូចជាការថតឆ្លុះសរសៃឈាមជាដើម។ ជាលទ្ធផលនៃការពិនិត្យបញ្ជាក់ថា រោគវិនិច្ឆ័យដែលអ្នកជំងឺមានបច្ចុប្បន្ននេះជាក់ស្តែងមានស្ថេរភាព និង មិនបង្កអោយមានការហាមឃាត់ជាពិសេសចំពោះជម្ងឺ នៅក្នុងលក្ខខណ្ឌនៃការឃុំខ្លួន ក៏ដូចជាក្នុងការចូលរួមរបស់ជននេះនៅក្នុងដំណើរការស៊ើបសួរឡើយ។ បើតាមយោបល់របស់អ្នកជំនាញ ដោយពិនិត្យលើអាយុរបស់គាត់ លោក នួន ជា រក្សាបាននូវស្វ័យភាពខាងបញ្ញាគ្រប់គ្រាន់ ។ ការតាមដានផ្នែកវេជ្ជសាស្ត្របានធ្វើជាប្រចាំ និងការធ្វើកោសល្យវិច័យថ្មីពី ២ ទៅ ៣ ដង ក្នុង ១ ឆ្នាំ នឹងត្រូវរៀបចំធ្វើឡើងជាបន្តបន្ទាប់។

2- **ការបំបែកសំណុំរឿង កាំង ហ្កេកអ៊ាវ ហៅ ឌុច**

ដោយយល់ឃើញថាការស៊ើបសួរលើអង្គហេតុ ដែលដាក់បន្ទុកលើ ឌុច នៅក្នុងក្របខ័ណ្ឌមន្ទីរ ស. ២១ នឹងអាចត្រូវបញ្ចប់នៅក្នុងប៉ុន្មានខែខាងមុខ (អាចនឹងបញ្ចប់ក្នុងឆមាសទី ១ ឆ្នាំ ២០០៨ ) សហចៅក្រមស៊ើបសួរ នៅក្នុងផលប្រយោជន៍នៃដំណើរការល្អក្នុងការស្វែងរកយុត្តិធម៌ បានសម្រេចក្នុងសេចក្តីសម្រេចចុះថ្ងៃទី ១៩ ខែកញ្ញា ឆ្នាំ ២០០៧ បង្គាប់ការបំបែកករណី ឌុច ចំពោះអង្គហេតុទាំងនេះ (សំណុំរឿងលេខ 001/18-07-2007 អ.វ.ត.ក /ការិយាល័យសហចៅក្រមស៊ើបសួរ) ដើម្បីអាចបញ្ចប់ការស៊ើបសួរលើផ្នែកនេះ ដោយមិនបាច់រង់ចាំលទ្ធផលនៃកិច្ចស៊ើបសួរបន្ថែមទាក់ទងនឹងអង្គហេតុផ្សេងទៀតដែលចោទឡើងនៅក្នុងដីកាបញ្ជូនរឿងអោយស៊ើបសួររបស់សហព្រះរាជអាជ្ញាចុះថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០០៧ ឡើយ (ដែលជាសំណុំរឿងលេខ ០០២/១៩-០៩-២០០៧ អ.វ.ត.ក /ការិយាល័យសហចៅក្រមស៊ើបសួរ) ។

3- **ការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី**

ក្រៅអំពីអង្គហេតុដែលប្រព្រឹត្តឡើងទាក់ទងនឹង ស. ២១ ការស៊ើបសួរដែលកំពុងដំណើរការផ្តោតលើអង្គហេតុ ៣ ប្រភេទធំៗ ៖ ការជម្លៀសប្រជាជនដោយបង្ខំ -មនុស្សឃាត និង ការរំលោភបំពានផ្សេងទៀតនៅក្នុងមន្ទីរសន្តិសុខ និង មន្ទីរឃុំឃាំងដ៏ទៃទៀត- ការធ្វើការដោយបង្ខំ ការឃុំឃាំងខុសច្បាប់ និង លក្ខខ័ណ្ឌរស់នៅអមនុស្សធម៌នៅទីកន្លែងផ្សេងទៀត។ ចំពោះរាល់សំណួរដែលទាក់ទងនឹងនីតិវិធីក្នុងការសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីចំពោះអង្គហេតុទាំងនេះ សូមពិនិត្យនៅក្នុងគេហទំព័ររបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាទាក់ទងនឹងអង្គភាពជនរងគ្រោះ (htt//www.eccc.gov.kh) ។ គេហទំព័រនេះនឹងដំណើរការនៅក្នុងពេលឆាប់ៗនេះ (សូមផ្ទៀងផ្ទាត់កាលបរិច្ឆេទនៅក្នុងគេហទំព័រ)។ ក្នុងអំឡុងពេលនេះ សំណើសុំព័ត៌មានអាចដាក់ជូន ឬទាក់ទងដោយផ្ទាល់មកក្រឡាបញ្ជីរបស់សហចៅក្រមស៊ើបសួរ។